| ៣៥- | លោក | ខៀវ | សំអឿន | ជាងដំឡើង-ជួសជុលកាប៉ាស៊ីទ័រ |
| ៣៦- | លោក | គុយ | ប៊ុណ្ណារ៉ា | ជាងជួសជុលអគ្គិសនី |
| ៣៧- | លោក | បាន | ស្រេង | ជាងជួសជុលយន្តសាស្ត្រ |
| ៣៨- | លោក | អ៊ីម | សុខុម | ជាងបន្តចរន្ត |
| ៣៩- | លោកស្រី | ជឹម | សុគន្ធ | បុគ្គលិករបៀប |
| ៤០- | លោក | ដួង | គីមអាន | បុគ្គលិកឃ្លាំង |
| ៤១- | លោក | សុខ | គន្ធរោ | បុគ្គលិកបំណុលរ៉ាំរ៉ៃ |
| ៤២- | លោកស្រី | ទា | ស៊ាន | ជាងដោះដាក់នាឡិការស្ទង់ |
| ៤៣- | លោក | ជា | រឿន | យន្តការី |
| ៤៤- | លោក | ម៉ម | ផល | បុគ្គលិកចែកវិក្កយបត្រ |
| ៤៥- | លោក | ហ៊ិន | ហាន | បុគ្គលិកជំរឿន |
| ៤៦- | លោក | អ៊ុង | គីមសឿន | បុគ្គលិកបញ្ជាចែកចាយចរន្ត |
| ៤៧- | លោក | នូ | សារៀន | ជាងជួសជុលទុយោវ៉ាន |
| ៤៨- | លោក | គុយ | កន | បុគ្គលិកបញ្ជាចែកចាយចរន្ត |
| ៤៩- | លោក | ខៀវ | សំអុល | ជាងកាត់និងភ្ជាប់ចរន្ត |
| ៥០- | លោកស្រី | សោម | កុលធីតា | បុគ្គលិកចែកវិក្កយបត្របំណុលរដ្ឋ |
| ៥១- | លោកស្រី | ជឹម | ស្ទូវ៉ន | បុគ្គលិកគ្រប់គ្រងឯកសារ |
| ៥២- | លោក | អ៊ុន | សារឿន | ជាងជួសជុល |
| ៥៣- | លោក | ទឹម | សារិន | ជាងបន្តចរន្ត |

| | | | | |
|---|---|---|---|---|
| ៥៤- | លោក | ឆួន | អេង | ជាងជួសជុល |
| ៥៥- | លោក | ប៊ុន | សារី | ជាងជួសជុលយន្តសាស្ត្រ |
| ៥៦- | លោក | ហម | ហែម | ជាងថែទាំបណ្តាញអាកាស |
| ៥៧- | លោក | ម៉ុំ | សុខលី | ជាងថែទាំសម្អាតបរិក្ខាតាមបន្ទប់ត្រង់ស្វូ |
| ៥៨- | លោក | ឡញ | ឡៃ | ជាងបញ្ជាចែកចាយចរន្ត |
| ៥៩- | លោកស្រី | ខៀវ | បូរី | បុគ្គលិកបេឡា |
| ៦០- | លោកស្រី | ជុំ | ប៊ុនហ្លួន | បុគ្គលិកបេឡា |
| ៦១- | លោក | មាន | ពិភព | បុគ្គលិកចែកវិក្កយបត្រ |
| ៦២- | លោក | វឿន | សារិន | ជាងជួសជុលយន្តសាស្ត្រ |
| ៦៣- | លោក | ឯម | ឈឿន | បុគ្គលិកត្រួតពិនិត្យ |
| ៦៤- | លោក | ខៀវ | សុខន | ជាងថែទាំបណ្តាញតង់ស្យុងទាប |
| ៦៥- | លោកស្រី | លិន | វណ្ណា | បុគ្គលិកទទួលអតិថិជន |
| ៦៦- | លោក | អ៊ឹង | ណយ | ជាងជួសជុល |
| ៦៧- | លោក | ទន់ | ទ្រី | ជាងបញ្ជាចរន្ត |
| ៦៨- | លោក | ប៉ែន | សារឿន | ជាងជួសជុលយន្តសាស្ត្រ |
| ៦៩- | លោក | ជា | សំណាង | ភ្នាក់ងារបន្តចរន្ត |
| ៧០- | លោក | ទុំ | ពិទូរ្យ | ភ្នាក់ងារត្រួតពិនិត្យ |
| ៧១- | លោក | ប៉ិយ | ចាន់ធូ | ជាងបញ្ជូនចែកចាយចរន្តវេនទី ៤ |
| ៧២- | លោក | ផា | សុផល | និយោជិតប្រចាំការ |
| ៧៣- | លោក | នេត | សារ៉ន | ជាងបញ្ជូនចែកចាយចរន្តវេនទី ១ |
| ៧៤- | លោក | សន | សុផល | ភ្នាក់ងារចែកវិក្កយបត្រ |
| ៧៥- | លោក | ហោ | សុវណ្ណា | បុគ្គលិកបញ្ជាចរន្តវេនទី ២ |
| ៧៦- | លោក | ម៉ិញ | លី | បុគ្គលិកស្ថានីយ៍បូមទឹកវេនទី ២ |
| ៧៧- | លោក | សំ | វុធថា | បុគ្គលិកបញ្ជាចរន្តវេនទី ២ |
| ៧៨- | លោក | វង | ស្រ៊ាន | បុគ្គលិកប្រចាំការស្ថានីយ៍បូមទឹកវេនទី ៣ |
| ៧៩- | លោក | យូ | ស៊ុយ | ជាងជួសជុល |
| ៨០- | លោក | កុយ | ចំរើន | ភ្នាក់ងារចែកវិក្កយបត្រ |
| ៨១- | លោក | ម៉ម | សំបូរ | បុគ្គលិកបញ្ជាចរន្តវេនទី ២ |
| ៨២- | លោក | ជា | ផាន់ណារ៉ា | ជាងថែទាំសម្អាតបរិក្ខាតាមបន្ទប់ត្រង់ស្វូ |
| ៨៣- | លោក | វ៉ាន់ | យូវ៉ាត | ជាងដំឡើង-ជួសជុលកាប៉ាស៊ីទ័រ |
| ៨៤- | លោក | ជូ | សុវណ្ណា | ជាងវាស់បន្ទុកត្រង់ស្វូ |

| | | | | |
|---|---|---|---|---|
| ៨៥- | លោក | ហួត | ស៊ីណាត | ជាងបញ្ជាចែកចាយចរន្តវេនទី ៤ |
| ៨៦- | លោក | អ៊ិត | ប៉ូ | ភ្នាក់ងាបន្តចរន្ត |
| ៨៧- | លោក | អ៊ុយ | ផល្លី | ជាងជួសជុលអគ្គិសនី |
| ៨៨- | លោក | ឈិត | សុភាព | បុគ្គលិកបើកបរម៉ាស៊ីន |
| ៨៩- | លោក | សេង | ហាង | បុគ្គលិកប្រចាំការស្ថានីយ៍បូមទឹក |
| ៩០- | លោក | នាក | បូ | ភ្នាក់ងារចែកវិក្កយបត្រ |
| ៩១- | លោក | ម៉ៃ | សំអឿន | ភ្នាក់ងារបន្តចរន្ត |
| ៩២- | លោក | សួស | សោភ័ណ | ភ្នាក់ងារចែកវិក្កយបត្រ |
| ៩៣- | លោក | សួន | ប៉ូញ | ជាងជួសជុលនិងថែទាំ |
| ៩៤- | លោក | ហែម | សុធា | បុគ្គលិកគិលានដ្ឋាន |
| ៩៥- | លោក | ប៉ូ | វណ្ណា | បុគ្គលិកបញ្ជាចែកចាយចរន្តវេនទី២ |
| ៩៦- | លោក | សយ | សំបូរ | បុគ្គលិកបញ្ជាចែកចាយចរន្តវេនទី២ |
| ៩៧- | លោក | ហង់ | សំអួន | បុគ្គលិកបញ្ជាចែកចាយចរន្តវេនទី២ |
| ៩៨- | លោក | ស៊ឹង | សម្បត្តិ | បុគ្គលិកអាជីវកម្ម |
| ៩៩- | លោក | វង្ស | ស៊ីម៉ុន | ជំនួយការក្រុមផលិតកម្ម |
| ១០០- | លោក | ហ៊ិន | សាន់ | បុគ្គលិកចែកវិក្កយបត្រ |
| ១០១- | លោក | ពៅ | សេរីវុធ | បុគ្គលិកគណនេយ្យ-ហិរញ្ញកិច្ច |
| ១០២- | លោក | មុត | សុខុម | បុគ្គលិកធ្វើវិក្កយបត្រនិងបំណុល |
| ១០៣- | លោក | អ៊ិន | ប៉ុន | បុគ្គលិកចែកវិក្កយបត្រ |
| ១០៤- | លោក | គិញ | សានី | បុគ្គលិកជួសជុលបណ្តាញ MV |
| ១០៥- | លោក | សាយ | ស៊ូឡេង | បុគ្គលិកផលិតកម្ម |
| ១០៦- | លោក | ប៊ុត | ខាំមុត | បុគ្គលិកផលិតកម្ម |
| ១០៧- | លោក | សុខ | វ៉ាន់នី | ជាងជួសជុលម៉ាស៊ីន |
| ១០៨- | លោក | ស៊ុត | ហោ | ជាងដំឡើង ជួសជុល និង ថែទាំបណ្តាញ |
| ១០៩- | លោក | ម៉ក់ | សុខា | បុគ្គលិកផលិតកម្ម |
| ១១០- | លោក | សូ | ញ៉ូន | បុគ្គលិកបើកបរម៉ាស៊ីននិងទូរបញ្ជា |
| ១១១- | លោក | សៅ | សារឹម | ជាងជួសជុលម៉ាស៊ីន |
| ១១២- | លោក | នាក់ | ផាន់ណា | និយោជិតឃ្លាំងសម្ភារ |
| ១១៣- | លោក | លាង | ស៊ាង | បុគ្គលិកបើកបរម៉ាស៊ីននិងទូរបញ្ជា |
| ១១៤- | លោក | តេង | ប៊ាង | បុគ្គលិករដ្ឋបាល |
| ១១៥- | លោក | លើវ | ឡិ | ជាងម៉ាស៊ីន |

| | | | | |
|---|---|---|---|---|
| ១១៦- | លោក | រស់ | ម៉ឺន | ជាងជួសជុលម៉ាស៊ីន |
| ១១៧- | លោកស្រី | ព្រំ | សុផល | បុគ្គលិកបេឡា |
| ១១៨- | លោក | យឹម | ហាង | ភ្នាក់ងារដំឡើងបណ្តាញ |
| ១១៩- | លោក | ងួន | ច័ន្ទរិទ្ធ | បុគ្គលិកបើកបរម៉ាស៊ីន |
| ១២០- | លោក | ង៉ែត | មាន | ភ្នាក់ងារដំឡើងជួសជុល |
| ១២១- | លោក | ឯម | ប៊ុនថន | បុគ្គលិកបើកបរម៉ាស៊ីន និង ទូរបញ្ជារវេនទី ៣ |
| ១២២- | លោក | តែ | គឹមសួន | បុគ្គលិកផ្នែកបណ្តាញខ្សែ |
| ១២៣- | លោក | ឈួន | កាមី | បុគ្គលិកទទួលព័ត៌មានទាន់ហេតុការណ៍ |
| ១២៤- | លោក | ធូ | ធិន | បុគ្គលិកទារប្រាក់ |
| ១២៥- | លោកស្រី | ប៉ែន | ស៊ីយ៉ាន | បុគ្គលិករដ្ឋបាលបេ |
| ១២៦- | លោក | ស្វាយ | ស៊ុនហេង | ជាងជួសជុលបណ្តាញ |
| ១២៧- | លោក | បោង | ខុន | ជាងជួសជុលថែទាំបណ្តាញ |
| ១២៨- | លោក | ចិន | ស៊ុន | ភ្នាក់ងារជួសជុល-ថែទាំបណ្តាញ |
| ១២៩- | លោក | ថែម | ហាក់ | បុគ្គលិកស្រង់ថាមពលអគ្គិសនី |
| ១៣០- | លោក | ឈឹម | សុផល | ជាងបញ្ជាចែកចាយចរន្តវេនទី ៤ |
| ១៣១- | លោក | ណុប | សុផល | កម្មករបើកបរម៉ាស៊ីន |
| ១៣២- | លោក | អន | ហន | កម្មករយាមម៉ាស៊ីន |
| ១៣៣- | លោក | អៀម | ធី | កម្មករប្រចាំការ |
| ១៣៤- | លោក | ឈាន | នី | កម្មករបន្ទប់បញ្ជា |
| ១៣៥- | លោក | ខឹម | ធឿន | កម្មករបណ្តាញ BT |
| ១៣៦- | លោក | នួន | ប៊ុនលី | កម្មករបើកបរម៉ាស៊ីន |
| ១៣៧- | លោក | រស់ | ស៊ីផាន់ | កម្មករជួសជុលយន្តសាស្ត្រ |
| ១៣៨- | លោក | គួច | ណាងស៊ា | កម្មករជួសជុលម៉ាស៊ីនGM |
| ១៣៩- | លោក | អោម | សុខុន | កម្មករយាមម៉ាស៊ីន |
| ១៤០- | លោក | ឃី | ផេង | កម្មករបញ្ជាម៉ាស៊ីន |
| ១៤១- | លោក | អៀង | សំអាង | កម្មករយន្តសាស្ត្រ |
| ១៤២- | លោក | ដួង | យ៉ង់ | កម្មកររកកំហូចកាប |
| ១៤៣- | លោក | ខឹម | លន់ | កម្មករយាមបូម |
| ១៤៤- | លោក | ហ៊ីង | សាន | កម្មករវេនផលិតកម្ម |
| ១៤៥- | លោក | ឌុច | ប៊ិន | កម្មករបណ្តាញ |
| ១៤៦- | លោក | ឈឿង | ឆាន | កម្មករផលិតកម្ម |

| | | | | |
|---|---|---|---|---|
| ១៤៧- | លោក | នួន | គីមស៊ិត | កម្មករបណ្តាញ |
| ១៤៨- | លោក | ឆោម | ឆាត់ | កម្មករប្រចាំការទ្វារចរន្ត |
| ១៤៩- | លោក | រាជ | យ៉ាត | កម្មករយន្តសាស្ត្រ |
| ១៥០- | លោកស្រី | ប៉ែន | រ៉េង | កម្មករអនាម័យ |
| ១៥១- | លោក | ប៉ាល់ | ឡេង | អ្នកបើកបររថយន្ត |
| ១៥២- | លោកស្រី | ពេញ | សូភី | កម្មករអនាម័យ |
| ១៥៣- | លោកស្រី | មុយ | យ៉ឹម | កម្មករអនាម័យ |
| ១៥៤- | លោកស្រី | អ៊ុំ | សុបិន្ត | កម្មករអនាម័យ |
| ១៥៥- | លោក | គីម | សាប៊ី | សន្តិសុខ |
| ១៥៦- | លោក | ឈឹម | ជីវ | កម្មករយាមបន្ទប់ |
| ១៥៧- | លោកស្រី | មុយ | ឃីម | កម្មករអនាម័យ |
| ១៥៨- | លោកស្រី | យ៉ឹម | សាលន | កម្មករអនាម័យ |
| ១៥៩- | លោកស្រី | កាំង | គីមទៀង | កម្មករអនាម័យ |
| ១៦០- | លោកស្រី | ខៀវ | ស៊ីណយ | កម្មករអនាម័យ |
| ១៦១- | លោកស្រី | ឃិន | លន | កម្មករអនាម័យ |
| ១៦២- | លោកស្រី | សុខ | ឃឿន | កម្មករអនាម័យ |
| ១៦៣- | លោកស្រី | អ៊ុន | សារុំ | កម្មករអនាម័យ |
| ១៦៤- | លោក | នួន | សេង | អ្នកបើកបររថយន្តប្រចាំការ |
| ១៦៥- | លោក | ឡុញ | ណម | សន្តិសុខ |
| ១៦៦- | លោក | នួន | សាវិន | អ្នកបើកបររថយន្ត |
| ១៦៧- | លោក | អ៊ុំ | លន់ | សន្តិសុខ |
| ១៦៨- | លោក | ទូច | ឈឿក | ឆ្មាំទ្វារ |
| ១៦៩- | លោក | គាវ | ឆាយ | សន្តិសុខ |
| ១៧០- | លោកស្រី | អ៊ុំ | សារិន | កម្មករអនាម័យ |
| ១៧១- | លោក | បេ | សំអាន | សន្តិសុខ |
| ១៧២- | លោក | ទឹម | សុវណ្ណ | អ្នកបើកបររថយន្ត |
| ១៧៣- | លោកស្រី | យិន | ភ្លួង | កម្មករអនាម័យ |
| ១៧៤- | លោក | មាស | ឆម | សន្តិសុខ |
| ១៧៥- | លោក | ខាន់ | សុខន | សន្តិសុខ |
| ១៧៦- | លោកស្រី | គីម | ប៊ាង | កម្មករអនាម័យ |
| ១៧៧- | លោក | អ៊ុន | ឆុន | សន្តិសុខ |

| | | | | |
|---|---|---|---|---|
| ១៧៨- | លោកស្រី | សុខ | ឡេងអេង | កម្មករអនាម័យ |
| ១៧៩- | លោកស្រី | យិន | ភុំ | កម្មករអនាម័យ |
| ១៨០- | លោកស្រី | សួស | សាផន | កម្មការិនីបោសសំអាត |
| ១៨១- | លោក | ចាន់ | ប៊ុនណាត | បើកបររថយន្ត |
| ១៨២- | លោក | ឆ្លួន | មឿន | សន្តិសុខ |
| ១៨៣- | លោក | ឈឹន | ប៊ុនណុំ | សន្តិសុខ |
| ១៨៤- | លោកស្រី | នៃ | សុមុនី | កម្មករអនាម័យ |
| ១៨៥- | លោក | អ៊ុន | ម៉ៅ | សន្តិសុខ |
| ១៨៦- | លោក | រស់ | ណែម | បើកបររថយន្ត |
| ១៨៧- | លោក | សួន | សាម៉េត | បើកបររថយន្ត |
| ១៨៨- | លោក | អ៊ុច | ឆាំ | សន្តិសុខ |
| ១៨៩- | លោក | ភោគ | សារី | សន្តិសុខ |
| ១៩០- | លោក | បាន | សារី | កម្មករអនាម័យ |
| ១៩១- | លោក | មាស | សារុំ | សន្តិសុខ |
| ១៩២- | លោក | អុំ | ហ៊ន | សន្តិសុខ |
| ១៩៣- | លោក | តឹក | ថុន | សន្តិសុខ |
| ១៩៤- | លោក | ម៉េង | ស្រេង | សន្តិសុខ |
| ១៩៥- | លោក | ពុប | ធី | សន្តិសុខ |
| ១៩៦- | លោក | លុក | ហ៊ឹម | សន្តិសុខ |
| ១៩៧- | លោក | ឃឹម | ចាន់ថា | បើកបររថយន្ត |
| ១៩៨- | លោក | វ៉ា | ណាល់ | សន្តិសុខ |
| ១៩៩- | លោក | បាន | ពេញ | បើកបររថយន្ត |
| ២០០- | លោក | ឃុញ | ញ៉ាញ់ | បើកបររថយន្ត |
| ២០១- | លោក | បាន | ងួន | សន្តិសុខ |
| ២០២- | លោក | ស៊ុន | លី | សន្តិសុខ |
| ២០៣- | លោក | ម៉ែន | អេង | សន្តិសុខ |
| ២០៤- | លោក | ឃុន | ផេង | អ្នកបើកបររថយន្ត |
| ២០៥- | លោក | តោ | ណុប | អ្នកបើកបររថយន្ត |
| ២០៦- | លោក | សាន់ | អន | សន្តិសុខ |
| ២០៧- | លោក | ភឿន | សុក្ខា | សន្តិសុខ |
| ២០៨- | លោក | មាន | យុង | កម្មករអនាម័យ |

២០៩- លោក ហង់ ហឿន សន្តិសុខ

២១០- លោក ហែម ឈុំ សន្តិសុខ

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ....៧៦...សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរនិងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស "គ.អ.ច.ទ.**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៣៤ សសរ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីសម្រួលការធ្វើដំណើរនិងដឹកជញ្ជូនភ្ញៀវទេសចរនិងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត
- យោងតាមសំណូមពរចាំបាច់នៃការងារ

**សម្រេច**

**ប្រការ១ .-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីសម្រួលការធ្វើដំណើរនិងដឹកជញ្ជូនភ្ញៀវទេសចរនិងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិនិងច្រកទ្វារអន្តរជាតិទូទាំងប្រទេស ហៅកាត់ **គ.អ.ច.ទ.** ដូចខាងក្រោម៖



២

១- ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ប្រធាន
២- ឯកឧត្តមនាយឧត្តមសេនីយ៍ **អ៊ុក គឹមលេខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
៣- ឯកឧត្តម **ស៊ូ សិរិទ្ធ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន
៤- ឯកឧត្តម **ជា ម៉ូរ៉ា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន
៥- ឯកឧត្តម **តូច ចាន់កុសល** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន អនុប្រធាន
៦- ឯកឧត្តមសាស្ត្រាចារ្យ **អេង ហួត** រដ្ឋលេខាធិការក្រសួងសុខាភិបាល អនុប្រធាន
៧- ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អនុប្រធាន
៨- ឯកឧត្តមនាយឧត្តមសេនីយ៍ **សុខ ផល** អគ្គនាយកនៃអគ្គនាយកដ្ឋាន
អន្តោប្រវេសន៍ក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍
៩- ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ឹម យ៉ាន** អគ្គស្នងការរងនគរបាលជាតិ
ក្រសួងមហាផ្ទៃ អនុប្រធាន
១០- ឯកឧត្តម **ប៉ា សុជាតិវង្ស** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ អនុប្រធាន
១១- ឯកឧត្តម **ឃឹម ប៊ុនសុង** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប អនុប្រធាន
១២- ឯកឧត្តម **ឈិត សុខុន** អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ អនុប្រធាន
១៣- ឯកឧត្តម **ជៀង អំ** អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង អនុប្រធាន
១៤- ឯកឧត្តម **ហាស់ សារ៉េត** អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង អនុប្រធាន
១៥- ឯកឧត្តម **ម៉ៅ ធីរុណា** អភិបាលនៃគណៈអភិបាលខេត្តកណ្តាល អនុប្រធាន
១៦- ឯកឧត្តម **ឡាយ វណ្ណៈ** អភិបាលនៃគណៈអភិបាលខេត្តតាកែវ អនុប្រធាន
១៧- ឯកឧត្តម **ខូយ ឃុនហ៊ួរ** អភិបាលនៃគណៈអភិបាលខេត្តកំពត អនុប្រធាន
១៨- ឯកឧត្តម **សរ ចំរុង** អភិបាលនៃគណៈអភិបាលខេត្តក្រចេះ អនុប្រធាន
១៩- ឯកឧត្តម **ប្រាជ្ញ ចន្ទ** អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ អនុប្រធាន
២០- ឯកឧត្តម **ថង សាវុន** អភិបាលនៃគណៈអភិបាលខេត្តរតនគិរី អនុប្រធាន
២១- ឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ អនុប្រធាន
២២- ឯកឧត្តម **គោសុំ សារឿត** អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ អនុប្រធាន
២៣- ឯកឧត្តម **ច័ន្ទ សុផល** អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង អនុប្រធាន
២៤- ឯកឧត្តម **អ៊ើត សុធា** អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន អនុប្រធាន
២៥- ឯកឧត្តម **ប៊ុន លើត** អភិបាលនៃគណៈអភិបាលខេត្តកោះកុង អនុប្រធាន
២៦- ឯកឧត្តម **អ៊ុំ ម៉ារ៉ា** អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ អនុប្រធាន
២៧- ឯកឧត្តម **ម៉ៅ ធនិន** អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ អនុប្រធាន
២៨- ឯកឧត្តម **គុល សំអុល** អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង អនុប្រធាន
២៩- ឯកឧត្តម **ហោ សារុន** អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិកអចិន្ត្រៃយ៍
៣០- ឯកឧត្តម **លេង វី** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
៣១- ឯកឧត្តម **លូ គឹមឈន់** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធាន
អគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ សមាជិក
៣២- ឯកឧត្តម **ហ៊ី បាវី** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធាន
អគ្គនាយកកំពង់ផែស្វយ័តរាជធានីភ្នំពេញ

៣៣- ឯកឧត្តម **ចាន់ តារា** អគ្គនាយកដឹកជញ្ជូនក្រសួងសាធារណការ
និងដឹកជញ្ជូន សមាជិក

៣៤- ឯកឧត្តម **ប្រាក់ សុណ្ណារ៉ា** អគ្គនាយកបេតិកភណ្ឌនៃក្រសួងវប្បធម៌
និងវិចិត្រសិល្បៈ សមាជិក

៣៥- ឯកឧត្តម **ហង្ស ម៉ុណ្ណារ៉ាក់** អគ្គនាយករងនៃក្រសួងរៀបចំដែនដី
នគរូបនីយកម្ម និងសំណង់ សមាជិក

៣៦- ឯកឧត្តមឧត្តមសេនីយ៍ឯក **ខៀវ ឆេន** អគ្គនាយករងនៃអគ្គនាយកដ្ឋាន
នយោបាយនិងកិច្ចការបរទេសក្រសួងការពារជាតិ សមាជិក

៣៧- ឯកឧត្តមឧត្តមសេនីយ៍ឯក **ពិន ពិសិដ្ឋ** អគ្គនាយករងនៃអគ្គនាយកដ្ឋាន
អន្តោប្រវេសន៍ក្រសួងមហាផ្ទៃ សមាជិក

៣៨- ឯកឧត្តមឧត្តមសេនីយ៍ឯក **ឃុន សំបូរ** អគ្គនាយករងនៃអគ្គនាយកដ្ឋាន
អន្តោប្រវេសន៍ក្រសួងមហាផ្ទៃ សមាជិក

៣៩- ឯកឧត្តមឧត្តមសេនីយ៍ឯក **សេក ត្មី** ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់
សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ សមាជិក

៤០- លោក **ឯមឃិន ថេរៈ** អគ្គនាយករងគយនិងរដ្ឋាករកម្ពុជានៃ
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៤១- លោក **ស៊ុំ ណារុន** អគ្គនាយករងនៃអគ្គនាយកដ្ឋានកាំកុងត្រូល
ក្រសួងពាណិជ្ជកម្ម សមាជិក

៤២- លោក **នឹម សុវណ្ណា** អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុនៃ
ក្រសួងទេសចរណ៍ សមាជិក

៤៣- លោក **ប្រាក់ ច័ន្ទតារា** អគ្គនាយករងទេសចរណ៍នៃក្រសួងទេសចរណ៍ សមាជិក

៤៤- លោក **ចិន សាម៉ន** អគ្គនាយករងទេសចរណ៍នៃក្រសួងទេសចរណ៍ សមាជិក

៤៥- លោកស្រី **ហោ សុខឌ្យនា** អនុប្រធាននាយកដ្ឋានធានារ៉ាប់រងនិងសោធន
នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិកា

៤៦- លោក **យឹម ភាណារ៉ាល់** អនុប្រធានការិយាល័យលិខិតឆ្លងដែននៃ
ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៤៧- លោក **ហ៊ុយ វ៉ាថារ៉ូ** តំណាងការិយាល័យជាតិធានារ៉ាប់រងកម្ពុជា
នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក។

**ប្រការ២ .-**

**គ.អ.ច.ឆ.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ជំរុញអនុវត្តសេចក្តីជូនដំណឹងលេខ៤១៣ សជណ.សរ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឲ្យមានប្រសិទ្ធភាព ដើម្បីរៀបចំរបៀបរៀបរយ សណ្តាប់ធ្នាប់ និងសម្រួលការដឹកជញ្ជូន និងការធ្វើដំណើររបស់ភ្ញៀវទេសចរនិងអ្នកដំណើរនៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតនិងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀតឲ្យបានល្អប្រសើរ

- សិក្សារៀបចំតំបន់ច្រកទ្វារព្រំដែនអន្តរជាតិនិងច្រកទ្វារអន្តរជាតិទូទាំងប្រទេសឲ្យមានហេដ្ឋារចនាសម្ព័ន្ធនិងរចនាសម្ព័ន្ធគ្រប់គ្រាន់ ដើម្បីសម្រួលដល់ការធ្វើដំណើរនិងដឹកជញ្ជូនអ្នកដំណើរនិងភ្ញៀវទេសចរ
- លុបបំបាត់និងបោសសម្អាតភាពអសកម្មទាំងឡាយនិងភាពអនាធិបតេយ្យគ្រប់បែបយ៉ាង ដែលនាំឲ្យប៉ះពាល់និងរំខានដល់ការធ្វើដំណើរនិងការដឹកជញ្ជូនអ្នកដំណើរនិងភ្ញៀវទេសចរ
- **គ.អ.ច.ឆ.** ត្រូវជួបប្រជុំរៀងរាល់៣ខែម្តង ដើម្បីត្រួតពិនិត្យ និងពង្រឹងគុណភាពការងារដែលមានចំពោះមុខ និងធ្វើការដោះស្រាយជាបន្ទាន់ចំពោះបញ្ហានានាដែលកើតមាន
- បូកសរុបលទ្ធផល និងធ្វើរបាយការណ៍ ដោយលើកយោបល់ជាវិធានការដោះស្រាយជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

**ប្រការ៣ .-**

**គ.អ.ច.ឆ.** មានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានសមាសភាព តួនាទី និងភារកិច្ចដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ហោ សារុន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| ២- លោក **ហេង សុខចំរើន** | អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ និងជានាយករងខុទ្ទកាល័យរដ្ឋមន្ត្រីនៃក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣- លោក **ចិន សាម៉ន** | អគ្គនាយករងទេសចរណ៍នៃក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤- លោកឧត្តមសេនីយ៍ទោ **ឆាយ ម៉ុណ្ណា** | ប្រធាននាយកដ្ឋានច្រកទ្វារទី១នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥- លោកឧត្តមសេនីយ៍ទោ **សារិន សារីណូ** | ប្រធាននាយកដ្ឋានច្រកទ្វារទី២នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៦- ឯកឧត្តម **ម៉ុន រដ្ឋា** | នាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ | អនុប្រធាន |
| ៧- ឯកឧត្តម **និត្យ វណ្ណា** | នាយកអាកាសយានដ្ឋានអន្តរជាតិសៀមរាប | អនុប្រធាន |
| ៨- លោក **ហ៊ុន ឈឿន** | នាយកអាកាសយានដ្ឋានអន្តរជាតិក្រុងព្រះសីហនុ | អនុប្រធាន |
| ៩- លោក **គង់ សុភារក្ស** | ប្រធាននាយកដ្ឋានស្ថិតិនិងព័ត៌មានទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិក |
| ១០- លោក **ខែន រតនា** | ប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាលនៃក្រសួងទេសចរណ៍ | សមាជិក |
| ១១- លោក **សំ ឧត្តរា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅនៃក្រសួងទេសចរណ៍ | លេខាធិការ |
| ១២- លោក **វិបុល អភិវឌ្ឍន៍** | អនុប្រធាននាយកដ្ឋានស្ថិតិនិងព័ត៌មានទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៣- លោក **ខួច បញ្ញាវុធ** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៤- លោកឧត្តមសេនីយ៍ត្រី **ហឿន សំអុល** | អនុប្រធាននាយកដ្ឋាននគរបាលទេសចរណ៍នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ | សមាជិក |

១៥- លោកវរសេនីយ៍ទោ **នួន ពិសិដ្ឋ** អនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ សមាជិក

១៦- លោក **តាំង សុចិត្រត្រីស្លា** ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ សមាជិក

១៧- លោក **ទ៉ូច សេងភាត់** ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប សមាជិក

១៨- លោក **ទូ សុផល** ប្រធានមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ សមាជិក

១៩- លោក **វ៉ាន់ សារ៉ាត់** ប្រធានមន្ទីរទេសចរណ៍ខេត្តស្វាយរៀង សមាជិក

២០- លោកស្រី **អេង ណាវី** ប្រធានមន្ទីរទេសចរណ៍ខេត្តព្រៃវែង សមាជិកា

២១- លោក **សំ សូតី** ប្រធានមន្ទីរទេសចរណ៍ខេត្តកណ្តាល សមាជិក

២២- លោក **ឯម សុវណ្ណារ៉ា** ប្រធានមន្ទីរទេសចរណ៍ខេត្តតាកែវ សមាជិក

២៣- លោក **សយ ស៊ីណុល** ប្រធានមន្ទីរទេសចរណ៍ខេត្តកំពត សមាជិក

២៤- លោក **រុន តារ៉ា** ប្រធានមន្ទីរទេសចរណ៍ខេត្តក្រចេះ សមាជិក

២៥- លោក **អឿន រិទ្ធ** ប្រធានមន្ទីរទេសចរណ៍ខេត្តត្បូងឃ្មុំ សមាជិក

២៦- លោក **ង៉ែត ពិទូ** ប្រធានមន្ទីរទេសចរណ៍ខេត្តរតនគិរី សមាជិក

២៧- លោកស្រី **ធិនធី មុន្នីរស្មី** ប្រធានមន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ សមាជិកា

២៨- លោក **ជង់ ឡឹម** ប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ សមាជិក

២៩- លោក **អ៊ុច អ៊ុំតីនីស្សារ៉ា** ប្រធានមន្ទីរទេសចរណ៍ខេត្តបាត់ដំបង សមាជិក

៣០- លោក **ហុង ឌុល** ប្រធានមន្ទីរទេសចរណ៍ខេត្តប៉ៃលិន សមាជិក

៣១- លោក **ប៊ុន បៀច** ប្រធានមន្ទីរទេសចរណ៍ខេត្តកោះកុង សមាជិក

៣២- លោក **គង់ វិបុល** ប្រធានមន្ទីរទេសចរណ៍ខេត្តព្រះវិហារ សមាជិក

៣៣- លោក **សំ ឃីម** ប្រធានមន្ទីរទេសចរណ៍ខេត្តពោធិ៍សាត់ សមាជិក

៣៤- លោក **អ៊ន់ ប៉ោសឿន** ប្រធានមន្ទីរទេសចរណ៍ខេត្តស្ទឹងត្រែង សមាជិក

៣៥- លោក **ប៉ែន សុវណ្ណា** ប្រធានការិយាល័យសរុបក្រសួងទេសចរណ៍ សមាជិក

៣៦- លោក **ជា ច័ន្ទមុន្នី** អនុប្រធានការិយាល័យចត្តាឡីស័កក្រសួងសុខាភិបាល សមាជិក

៣៧- លោក **ជៀប ម៉េងហុង** នាយរងការិយាល័យនៃអធិការដ្ឋានក្រសួងទេសចរណ៍ សមាជិក

៣៨- លោក **ហោ សុផារុន** មន្ត្រីនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាន ក្រសួងទេសចរណ៍ សមាជិក

៣៩- កញ្ញា **ជាង មុយឆាង** មន្ត្រីនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅក្រសួងទេសចរណ៍ សមាជិកា

៤០- កញ្ញា **ពេជ្រ ស្រីណុច** មន្ត្រីនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅក្រសួងទេសចរណ៍ សមាជិកា។

លេខាធិការដ្ឋាន**គ.អ.ច.ឧ.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- តាមដានរាល់សកម្មភាពគ្រប់ច្រកទ្វារព្រំដែនអន្តរជាតិនិងច្រកទ្វារអន្តរជាតិទូទាំងប្រទេសក្នុងការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជានិងលិខិតបទដ្ឋាននានារបស់គណៈកម្មាធិការក្រសួង

- រៀបចំធ្វើការបណ្តុះបណ្តាលមុខជំនាញបដិសណ្ឋារកិច្ចនិងសេវាកម្មភ្ញៀវទេសចរជូនដល់ប្រតិបត្តិករទេសចរណ៍ និងសមត្ថកិច្ចតាមច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិ
- ចុះធ្វើការងារនៅតាមច្រកទ្វារព្រំដែនអន្តរជាតិនិងច្រកទ្វារអន្តរជាតិទូទាំងប្រទេសក្នុងមួយខែម្តង ដើម្បីធ្វើការបូកសរុបរបាយការណ៍ជូនគណៈកម្មការអន្តរក្រសួងក្នុងកិច្ចប្រជុំបីខែម្តង
- បូកសរុបលទ្ធផលការងារអនុវត្តរបស់គណៈកម្មការអន្តរក្រសួងរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលកម្ពុជា។

**ប្រការ៤ .–**

**គ.អ.ច.ឆ.** មានសិទ្ធិប្រើត្រារបស់ក្រសួងទេសចរណ៍ដើម្បីដំណើរការការងាររបស់ខ្លួនតាមការចាំបាច់។

សមាជិក **គ.អ.ច.ឆ.** ទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាននិងអាចប្រើមន្ត្រីក្នុងអង្គភាពរបស់ខ្លួនបន្ថែមទៀតតាមសំណូមពរនិងទំហំការងារជាក់ស្តែង។

**ប្រការ៥ .–**

សេចក្តីសម្រេចលេខ៣៤ សសរ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរនិងដឹកជញ្ជូនភ្ញៀវទេសចរនិងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតនិងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ៣ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ខែ ឧសភា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៧៥ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការកែសម្រួលសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទីភារកិច្ច និងរបៀបរបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានផ្លាស់ប្តូរ បំពេញបន្ថែម ឯកឧត្តម អស់លោក ជាអនុប្រធាន និងសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅតាមបណ្តា រាជធានី ខេត្ត មួយចំនួនដូចខាងក្រោម ៖

១- **ឯកឧត្តម គន់ វ៉ាន់ថារ៉ា** រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយមសមាជិកក្រុមការងារខេត្តកំពង់ចាម ផ្ទេរមកជាសមាជិកក្រុមការងារ ខេត្តបាត់ដំបង និងជាអនុប្រធានក្រុមការងារស្រុកថ្មគោល។

២-**លោក ម៉ិល ដៃលលី** អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស ក្រសួងធនធានទឹក និងឧតុនិយម សមាជិកក្រុមការងារខេត្តព្រៃវែង ផ្ទេរមកជាសមាជិកក្រុមការងារខេត្តបាត់ដំបង និងជាសមាជិកក្រុមការងារចុះស្រុកថ្មគោល។

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលរាជធានី ខេត្ត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ២០១៥

**តប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**ស ខេង**

<u>*កន្លែងទទួលៈ*</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម*
*លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួងស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៣៧.សសរ**

**សេចក្តីសម្រេច**
**ស្តីពី**
**ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិ**
**ដើម្បីអនុវត្តផែនការសកម្មភាពស្តីពីយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច**
**អាយេយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការជាតិ ដើម្បីអនុវត្តផែនការសកម្មភាពស្តីពីយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អាយេយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ (Ayeyawady-Chao Phraya-Mekong Economic Cooperation Strategy - ACMECS) ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ហោ ណាំហុង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២. ឯកឧត្តម | **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣. ឯកឧត្តម | **សាយ សំអាល់** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| ៤. ឯកឧត្តម | **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | | | | |
|---|---|---|---|---|
| ៥. | ឯកឧត្តម | **ម៉ៅ ថូរ៉ា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦. | ឯកឧត្តម | **ឯក សុនចាន់** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៧. | ឯកឧត្តម | **សុខ ខាវ៉ាន់** | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៨. | ឯកឧត្តម | **សុខុម គគវន្តមុនី** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៩. | ឯកឧត្តម | **អេង ហួត** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១០. | ឯកឧត្តម | **ទី សុគន្ធ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១. | ឯកឧត្តម | **ណាត ម៉ិនឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១២. | ឯកឧត្តម | **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា អគ្គលេខាធិការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | លេខាធិការប្រតិបត្តិ។ |

**ប្រការ២.-**

គណៈកម្មការជាតិនេះមានភារកិច្ចដូចតទៅ ៖

- ពិភាក្សាជាមួយប្រទេសជាដៃគូ ក្នុងយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ជាពិសេសជាមួយប្រទេសថៃ ដើម្បីជំរុញការអនុវត្តផែនការសកម្មភាព ឱ្យស្របតាមពេលវេលាកំណត់
- អាចលើកគម្រោងចរចាដោយផ្ទាល់ រវាងស្ថាប័នពាក់ព័ន្ធក្នុងយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដើម្បីជំរុញការអនុវត្តផែនការសកម្មភាព
- អាចពិភាក្សាលើកគម្រោងផ្សេងទៀត ក្រៅពីផែនការសកម្មភាពស្តីពីយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ស្នើជូនរាជរដ្ឋាភិបាលដើម្បីបញ្ចូលក្នុងផែនការសកម្មភាពទៅអនាគត
- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច។

**ប្រការ៣.-**

គណៈកម្មការជាតិនេះ មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ ឬតំណាងក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធនឹងការងារក្នុងក្របខណ្ឌយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អាយ៉េយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ (ACMECS) ឬការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិ ដើម្បីចូលរួមបំពេញការងារ តាមការជាក់ស្តែង។

**ប្រការ៤.-**

សមាជិកទាំងអស់នៃគណៈកម្មការជាតិនេះ ត្រូវចូលរួមប្រជុំ និងធ្វើការងារតាមសេចក្តីអញ្ជើញ និងការណែនាំរបស់ប្រធាន។

**ប្រការ៥.-**

គណៈកម្មការជាតិនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាផ្លូវការ។

**ប្រការ៦.-**

គណៈកម្មការជាតិនេះមានលេខាធិការដ្ឋានមួយ ដែលស្ថិតនៅក្នុងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**ប្រការ៧.-**

សេចក្តីសម្រេចលេខ៧៥ សសរ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការបង្កើតគណៈកម្មការជាតិដើម្បីអនុវត្តផែនការសកម្មភាពស្តីពីយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច បួនប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងថៃ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧៩...សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតអនុគណៈកម្មាធិការបច្ចេកទេសចម្រុះ**

**នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចលេខ ១៤៨សសរ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសចម្រុះទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នា លើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ
- បានឃើញតម្រូវការចាំបាច់ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**សម្រេច**

**ប្រការ ១:** បង្កើតអនុគណៈកម្មាធិការបច្ចេកទេសចម្រុះ នៅក្នុងតំបន់ទាមទារ ដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ ដែលមានសមាសភាពដូចតទៅ÷

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ហួ ទិចិត្រ** | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | ប្រធាន |
| ២- | ឯកឧត្តម | **ឡុង វិសាលោ** | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការ | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៣- | ឯកឧត្តម | **នាង ផាត** | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | អនុប្រធាន |
| ៤- | ឯកឧត្តម | **តឹករ៉េត សំរេច** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- | ឯកឧត្តម | **សុខ ខាវ៉ាន់** | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៦- | ឯកឧត្តម/លោកជំទាវ ឯកអគ្គរាជទូត ប្រចាំព្រះរាជាណាចក្រថៃ | | | សមាជិក |
| ៧- | ឯកឧត្តម | **ឡាំ ជា** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៨- | ឯកឧត្តម | **អ៊ិត សុត្ថា** | ទីប្រឹក្សាអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន និងជាអនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៩- | ឯកឧត្តម | **កៅ ឆារ៉ូ** | អនុរដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១០- | ឯកឧត្តម | **ឃុន បូរិន្ទ** | អគ្គលេខាធិការរង គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ | សមាជិក |
| ១១- | ឯកឧត្តម | **ស៊ា ម៉ៅ** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១២- | ឯកឧត្តម | **ជៀប សួរ** | អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៣- | ឯកឧត្តម | **គង់ ច័ន្ទទាសនា** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក និងជាលេខាធិការ |
| ១៤- | ឯកឧត្តម | **ហាក់ សុខហេង** | អគ្គលេខាធិការរង ក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក និងជាលេខាធិការ |
| ១៥- | លោក | **ជា សុជាតិ** | ប្រធាននាយកដ្ឋានកិច្ចការប្រេងកាតអន្តរជាតិ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៦- | លោក | **កែវ ទិសិដ្ឋ** | ប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៧- | លោក | **ហួយ ទុត្ថា** | ប្រធាននាយកដ្ឋានសិក្សាស្រាវជ្រាវប្រេងកាត ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៨- | លោកស្រី | **យ៉ែម កាន់នីកា** | ប្រធាននាយកដ្ឋាននីតិកម្ម ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៩- | លោក | **លឹម វត្ថា** | អនុប្រធាននាយកដ្ឋានកិច្ចការប្រេងកាតអន្តរជាតិ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២០- | លោក | **កែវ ទិសិដ្ឋ** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងព័ត៌មានវិទ្យា ក្រសួងរ៉ែ និងថាមពល | សមាជិក និងជាលេខាធិការ |

**ប្រការ ២:** អនុគណៈកម្មាធិការបច្ចេកទេសចម្រុះ នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ មានភារកិច្ចដូចតទៅ÷

(ក)- ជាយន្តការឆ្លើយតប ក្នុងកិច្ចសហប្រតិបត្តិការ ជាមួយព្រះរាជាណាចក្រថៃ ក្នុងដំណើរការចរចា ដោះស្រាយតំបន់ដែនសមុទ្រទាមទារត្រួតគ្នា។

(ខ)- ជាយន្តការសមភាគីជាមួយអនុគណៈកម្មាធិការបច្ចេកទេសចម្រុះថ្មី ដែលព្រះរាជាណាចក្រថៃ ទើបនឹងបង្កើតឡើង។

**ប្រការ ៣**: គ្រប់សមាជិកនៃអនុគណៈកម្មាធិការបច្ចេកទេសចម្រុះ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញ របស់ប្រធាន ឬ អនុប្រធាន។

**ប្រការ ៤**: អនុគណៈកម្មាធិការបច្ចេកទេសចម្រុះ មានទីស្នាក់ការរបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រា របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ ៥**: អនុគណៈកម្មាធិការបច្ចេកទេសចម្រុះ មានសិទ្ធិប្រើប្រាស់មូលនិធិរបស់គណៈកម្មាធិការបច្ចេកទេសចម្រុះ ទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នា លើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ សម្រាប់បំពេញការងាររបស់ខ្លួន។

**ប្រការ ៦**: សេចក្តីសម្រេចលេខ ០៧ សសរ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០២ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៣...សរណ..

# សារាចរ

## ស្តីពី

## ការចាត់តាំងខួបលើកទី៦៦ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី១៤ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៥

ជារៀងរាល់ឆ្នាំ ព្រះរាជាណាចក្រកម្ពុជាតែងប្រារព្ធ**ទិវាកុមារអន្តរជាតិ ១មិថុនា ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជា** ដើម្បីរំលឹកដល់ការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់កុមារ និងបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលចំពោះកុមារ ស្របតាមរដ្ឋធម្មនុញ្ញ អនុសញ្ញាស្តីពីសិទ្ធកុមាររបស់អង្គការសហប្រជាជាតិ អនុសញ្ញាលេខ១៨២ របស់អង្គការពលកម្មអន្តរជាតិស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងបទដ្ឋានជាតិ អន្តរជាតិស្តីពីសិទ្ធិកុមារផ្សេងៗទៀត។

ការប្រារព្ធទិវាកុមារអន្តរជាតិ១មិថុនា គឺដើម្បីរំលឹកនូវព្រឹត្តិការណ៍វិនាសកម្មរបស់ពួកហ្វាសស៊ីសអ៊ីត្លែរ ដែលបានកាប់សម្រាប់ស្ត្រី និងកុមារនៅភូមិលីឌីសែ ប្រទេសឆេក និងនៅភូមិអូរាឌូ ប្រទេសបារាំង ក្នុងអំឡុងឆ្នាំ១៩៤២-១៩៤៤ នៃសង្គ្រាមលោកលើកទី២ និងបានរួមគ្នាទប់ស្កាត់អំពើហិង្សា ដើម្បីថែរក្សាសន្តិភាពពិភពលោក និងជំរុញការអនុវត្តសិទ្ធិកុមារនៅគ្រប់ប្រទេស។

ការប្រារព្ធ**ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា** គឺបង្កើនចលនាពិភពលោកប្រឆាំងពលកម្មកុមារ ដែលបានស្តែងឱ្យឃើញតាមរយៈការផ្តល់សច្ចាប័នអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងអនុសញ្ញាលេខ១៣៨ ស្តីពីអាយុអប្បបរមាសម្រាប់ចូលធ្វើការដោយប្រទេសជាច្រើនលើពិភពលោក សំដៅទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ ដូចជាទាសករកុមារ ការជួញដូរកុមារ ពេស្យាចារកុមារ ការប្រើប្រាស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងក្នុងស្ថានភាពងាយរងគ្រោះ។ ទិវានេះក៏ដើម្បីបំផុសឱ្យមានការគាំទ្របន្ថែមពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀតផងដែរ។

ព្រះរាជាណាចក្រកម្ពុជា ធ្លាប់បានទទួលរងនូវមហាវិនាសកម្មដ៏ធ្ងន់ធ្ងរ ដែលបង្កឡើងដោយរបបប្រល័យពូជសាសន៍ **ប៉ុល ពត** ដែលបានកាប់សម្លាប់ប្រជាជនរាប់លាននាក់ និងបំផ្លាញសង្គមជាតិខ្ទេចខ្ទីដល់ឫសគល់ ក្នុងនោះកុមារក៏ត្រូវទទួលនូវការកាប់សម្លាប់ ធ្វើទារុណកម្ម បង្ខំឱ្យធ្វើការជាទម្ងន់ បង្អត់អាហារ រស់នៅយ៉ាងលំបាកវេទនាដោយអយុត្តិធម៌។ ក្រោយថ្ងៃរំដោះ ៧ ខែមករា ឆ្នាំ១៩៧៩ សិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងនោះរួមមានសិទ្ធិរបស់កុមារផង ត្រូវបានការពារ និងលើកតម្កើង ដោយមានចែងយ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញ កម្មវិធីនយោបាយ ផែនការ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិជាច្រើនជាអាទិ៍៖ អនុសញ្ញាស្តីពីសិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ពិធីសារបន្ថែមស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងពិធីសារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ នៅឆ្នាំ២០០២ អនុសញ្ញាលេខ២៩ ស្តីពីការងារដោយបង្ខំ ឬជាកាតព្វកិច្ច នៅឆ្នាំ១៩៧០ អនុសញ្ញាលេខ១៣៨ ស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការនៅឆ្នាំ១៩៩៩ អនុសញ្ញាលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅឆ្នាំ២០០៥ និងអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការសុំកូនអន្តរប្រទេសនៅឆ្នាំ២០០៧។

រាជរដ្ឋាភិបាលបានចេញសេចក្តីថ្លែងការណ៍ស្តីពីកម្ពុជាដើម្បីកុមារនៅឆ្នាំ២០០៤ បានបង្កើតគោលនយោបាយច្បាប់ជាតិ លិខិតបទដ្ឋាន និងផែនការសកម្មភាពជាតិពាក់ព័ន្ធនឹងកុមារ មានជាអាទិ៍៖ យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ គោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ គោលនយោបាយថែទាំជំនួសចំពោះកុមារ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ បទដ្ឋាននិងគោលការណ៍ណែនាំសម្រាប់ការថែទាំ ការគាំទ្រ និងការការពារចំពោះកុមារកំព្រានិងកុមារងាយរងគ្រោះ គោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរនៃព្រះរាជាណាចក្រកម្ពុជា និងនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសវៀតណាម ប្រទេសថៃ កិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសមហាអនុតំបន់មេគង្គ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីក្នុងការលុបបំបាត់ការជួញដូរ កុមារនិងស្ត្រី និងការជួយជនរងគ្រោះ ព្រមទាំងបានបង្កើតយន្តការជាច្រើននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អនុគណៈកម្មការជាតិពលកម្មកុមារនិងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ ក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់រាជធានី ខេត្ត និងគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច ក្នុងទិសដៅជំរុញការអនុវត្តសិទ្ធិកុមារ។

រាជរដ្ឋាភិបាលបានបង្កើនថវិកាលើវិស័យសង្គមកិច្ច អប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ កសិកម្ម និងវិស័យមួយចំនួនទៀត ក្នុងគោលដៅធ្វើឱ្យសុខុមាលភាពប្រជាជនកាន់តែប្រសើរឡើង ជាពិសេសចំពោះកុមារ និងសម្រេចបានគោលដៅជាច្រើននៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ អាត្រាមរណៈមាតា និងទារក ត្រូវបានកាត់បន្ថយ ការផ្តល់វ៉ាក់សាំង ថ្នាំបង្ការជំងឺដល់កុមារ ការសិក្សាអប់រំ ការការពារកុមារប្រឆាំងនឹងអំពើរំលោភបំពានផ្សេងៗ ត្រូវបានយកចិត្តទុកដាក់ជំរុញឱ្យកាន់តែប្រសើរឡើងជាលំដាប់។

ទោះបីយ៉ាងនេះក្តី កុមារកម្ពុជានៅប្រឈមមុខជាមួយនឹងបញ្ហាមួយចំនួននៅឡើយ ដូចជាអំពើហិង្សាលើកុមារ ការប្រើប្រាស់គ្រឿងញៀន អនីតិជនទំនាស់នឹងច្បាប់ អំពើជួញដូរកុមារ ពលកម្មកុមារ កុមារកង្វះអាហារូបត្ថម្ភ កុមារបោះបង់ចោលការសិក្សា កុមារចំណាកស្រុក។ល។ ដែលតម្រូវឱ្យយើងទាំងអស់គ្នារួមគ្នាដោះស្រាយឱ្យបានទាន់ពេលវេលា និងចំគោលដៅ។ ដើម្បីជំរុញការអនុវត្តសិទ្ធិកុមារឱ្យកាន់តែល្អប្រសើរឡើងថែមទៀត រាជរដ្ឋាភិបាលសូមធ្វើការណែនាំចាត់តាំង**ខួបលើកទី៦៦ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី១៤ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៥**នេះ ដូចតទៅ៖

**១**.ប្រធានបទនៃការប្រារព្ធខួបលើកទី៦៦ ទិវាកុមារអន្តរជាតិ១មិថុនា ទិវាកុមារកម្ពុជា និងខួបលើកទី១៤ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ គឺ *"លើកកម្ពស់អាហារូបត្ថម្ភប្រកបដោយគុណភាព ដើម្បីអភិវឌ្ឍកុមារ"* និង *"គ្មានពលកម្មកុមារ ផ្តល់ការអប់រំដែលមានគុណភាព"* ។

**២**.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ សាលារាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំមីទ្ទិញថ្នាក់ជាតិ និងរៀបចំកម្មវិធីកម្សាន្តផ្សេងៗសម្រាប់កុមារនៅរាជធានីភ្នំពេញ។

**៣.**ក្រសួងព័ត៌មានត្រូវសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ណែនាំប្រព័ន្ធឃោសនារដ្ឋ និងឯកជន ឱ្យធ្វើការផ្សព្វផ្សាយដល់សង្គមជាតិទាំងមូល ឱ្យបានជ្រួតជ្រាបពីប្រវត្តិនៃ**ទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាកុមារកម្ពុជា រួមទាំងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា** ផងដែរ។

**៤.**គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវរៀបចំពិធីមីទិញ ពិធីជួបសំណេះសំណាលជាមួយកុមារ កម្មវិធីកម្សាន្តសប្បាយរបស់កុមារ នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសិក្សារដ្ឋ ឯកជន អង្គការមិនមែនរដ្ឋាភិបាល និងគ្រប់មណ្ឌលកុមារកំព្រា នៅក្នុងមូលដ្ឋានរៀងៗខ្លួន។

**៥.**គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈ ឯកជន ត្រូវរៀបចំចងបដា ពាក្យស្លោក ដើម្បីអបអរសាទរខួបលើកទី៦៦ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី១៤ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៥ នេះ ដូចតទៅ៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរខួបលើកទី៦៦ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី១៤ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៥
- លើកកម្ពស់អាហាររូបត្ថម្ភប្រកបដោយគុណភាព ដើម្បីអភិវឌ្ឍន៍កុមារ
- គ្មានពលកម្មកុមារ ផ្តល់ការអប់រំដែលមានគុណភាព
- លើកកម្ពស់ការចូលរួមរបស់កុមារ ដើម្បីអភិវឌ្ឍសង្គម
- កុមារគឺជាធនធានសម្រាប់ការអភិវឌ្ឍសង្គម
- ផ្តល់ការថែទាំអប់រំដល់កុមារ ជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ
- អាហារូបត្ថម្ភល្អដើម្បីអនាគតដ៏ប្រសើរសម្រាប់កុមារ
- រួមគ្នាលុបបំបាត់ពលកម្មកុមារដើម្បីសិទ្ធិមនុស្ស និងយុត្តិធម៌សង្គម
- កុមារជាទំពាំងស្នងឫស្សី ជាអនាគតរបស់ប្រទេសជាតិ
- កុមារបើល្អ កូនល្អ សិស្សល្អ មិត្តល្អ ជាអនាគតពលរដ្ឋល្អ

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ សាលារាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
